**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**
**លេខ:០០៩/០៨ របក.អគគ**

## របាយការណ៍ស្តីពីសកម្មភាពការងារប្រចាំខែ មីនា ឆ្នាំ ២០០៨ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌និងទិសដៅសម្រាប់អនុវត្តបន្ត

ក្នុងខែ មីនា ឆ្នាំ ២០០៨ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោង ជាអង្គភាពប្រតិបត្តិ បានដំណើរការងាររបស់ខ្លួន ស្របតាមបេសកកម្មដែលបានកំណត់ ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែងដូចខាងក្រោម ៖

**១-ការងារកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**

**ក. ការងាររដ្ឋបាល**

-លិខិតស្នើបញ្ជូនសាលដីការដ្ឋប្បវេណី និងព្រហ្មទណ្ឌប្រចាំត្រីមាសទី ១ និងត្រីមាសទី ២ ឆ្នាំ២០០៧ របស់តុលាការកំពូលសម្រាប់ចងក្រងជាព្រឹត្តិបត្រ៍សាលដីកា

-លិខិតអញ្ជើញចូលរួមសិក្ខាសាលា ស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ ជាមួយភ្នាក់ងារអនុវត្តនានា និងសង្គមស៊ីវិល នៅតាមបណ្តាខេត្ត-ក្រុងទាំងឡាយ ដើម្បីពិចារណារកវិធីសាស្ត្រដែលល្អប្រសើរសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅសណ្ឋាគារសាន់វេ នៅថ្ងៃពុធ ទី២៦ ខែមីនា ឆ្នាំ២០០៨ វេលាម៉ោង ៧:៣០ ព្រឹក ដល់ ម៉ោង ១៧:០០ ល្ងាច

-លិខិតស្នើបញ្ជូនលោក ឆុង ហួត ឱ្យទៅចូលរួមវគ្គបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងហិរញ្ញប្បទានសហប្រតិបត្តិការ នៅទីក្រុងម៉ានីលប្រទេសហ្វីលីពីន

-លិខិតស្នើរៀបចំសិក្ខាសាលា ស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្តនានា និងសង្គមស៊ីវិលនៅតាមបណ្តាខេត្ត លើការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅខេត្តកំពង់ធំ នៅថ្ងៃព្រហស្បត៍ ទី១០ ខែមេសា ឆ្នាំ២០០៨, នៅខេត្តសៀមរាប នៅថ្ងៃទី ២២ ខែមេសា ឆ្នាំ២០០៨, នៅខេត្តបាត់ដំបង នៅថ្ងៃពុធ ទី៣០ ខែមេសា ឆ្នាំ២០០៨ និងនៅក្រុងព្រះសីហនុ នៅថ្ងៃទី៨ ខែឧសភា ឆ្នាំ២០០៨។

-លិខិតអញ្ជើញចូលរួមប្រជុំក្រុមការងារបច្ចេកទេសចម្រុះកំណែទម្រង់ច្បាប់ និងតុលាការ (TWG/LJR)នៅថ្ងៃទី ៧ ខែមេសា ឆ្នាំ២០០៨ វេលាម៉ោង ១៤:៣០ រសៀល។

**ខ. ការងារកំណែទម្រង់**

-ទទួលជួបក្រុមការងាររបស់កម្មវិធី CCJAPIII ស្វែងយល់ពីការងារសម្របសម្រួល និង យន្តការប្រមូលទិន្នន័យ

-ចូលរួមពិនិត្យសេចក្តីព្រាងផែនការប្រចាំឆ្នាំ ២០០៨-២០០៩ របស់ CCJAPIII

-រៀបចំសិក្ខាសាលាស្តីពី កម្មវិធីផ្លាស់ប្តូរយោបល់ជាមួយភ្នាក់ងារអនុវត្តនានា និងសង្គមស៊ីវិលនៅតាម បណ្តាខេត្ត-ក្រុងទាំងឡាយ ដើម្បីពិចារណារកវិធីសាស្ត្រដែលល្អប្រសើរសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ នៅសណ្ឋាគារសាន់វេ នៅថ្ងៃពុធ ទី២៦ ខែមីនា ឆ្នាំ២០០៨ វេលាម៉ោង ៧ៈ៣០ ព្រឹក ដល់ ម៉ោង ១៧ៈ០០ ល្ងាច

-ជួបជាមួយអ្នកឯកទេសមកពី EU ដើម្បីពិភាក្សាលើលទ្ធភាពរបស់ EU ក្នុងការជួយឧបត្ថម្ភដល់កំណែទម្រង់ច្បាប់ និងតុលាការ

-ពិភាក្សារៀបចំជាមួយ UNDP បន្តជំនួយដល់គម្រោងប្រមូលទិន្នន័យការបណ្តុះបណ្តាលសិទ្ធិមនុស្ស

-ប្រជុំក្រុមគម្រោង PMU រៀបចំប្រព័ន្ធសូចនាករតាមដានការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និង តុលាការ

-ជួបជាមួយប្រធាន EWMI ដើម្បីពិភាក្សាអំពីលទ្ធភាពបន្តកិច្ចសហការទៅអនាគត

-រៀបចំតារាងភាពជឿនលឿននៃការអនុវត្តផែនការជាតិជូនក្រសួងផែនការ

-ចូលរួមប្រជុំ GDCC នៅថ្ងៃអង្គារ ទី៤ ខែមីនា ឆ្នាំ២០០៨។

**គ. ផ្សេងៗ**

-ចូលរួមប្រជុំពិនិត្យរបាយការណ៍តាមក្រសួង សម្រាប់សន្និសីទស្តីពីលទ្ធផលការងាររបស់រដ្ឋាភិបាល ២០០៤-២០០៨ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០០៨

-ចូលរួមប្រជុំជាមួយក្រុមអគ្គលេខាធិការដ្ឋានកំណែទម្រង់រដ្ឋបាល ពិនិត្យរបាយការណ៍ស្តីពីការអនុវត្ត កម្មវិធី GAPII

-ចូលរួមប្រជុំអន្តរក្រសួងផ្សេងៗ។

**២-សន្និដ្ឋាន**

ក្នុងខែ មីនា ឆ្នាំ ២០០៨ នេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ជាអ្នកសម្របសម្រួលដំណើរការប្រចាំថ្ងៃ និងមានអង្គភាពគ្រប់គ្រងគម្រោងជាអង្គភាពប្រតិបត្តិ បានអនុវត្តនូវការងារសំខាន់ ២ គឺរៀបចំសិក្ខាសាលាផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិល លើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ និងការប្រជុំផ្ទៃក្នុង PMU ដើម្បីរៀបចំតារាងសូចនាករសម្រាប់តាមដាន កំណែទម្រង់ច្បាប់ និងតុលាការ។

**៣-ទិសដៅអនុវត្តក្នុងខែបន្ត**

-បន្តជម្រុញការអនុវត្តគម្រោងតុលាការគំរូ

-បន្តជម្រុញការអនុវត្តគម្រោងប្រព័ន្ធសូចនាករ និងការតាមដាន

-បន្តការពិភាក្សា ជាមួយ UNDP លើការឧបត្ថម្ភបន្តលើគម្រោងរៀបចំប្រព័ន្ធទិន្នន័យ

-រៀបចំសិក្ខាសាលាស្តីពីកម្មវិធីផ្លាស់ប្តូរយោបល់ជាមួយស្ថាប័នអនុវត្ត និងសង្គមស៊ីវិលលើការអនុវត្តកម្មវិធីកំណែទម្រង់ច្បាប់ និងតុលាការ នៅតាមបណ្តាខេត្តមួយចំនួនទៀត ដូចជា ខេត្តកំពង់ធំ ខេត្តសៀមរាប ខេត្តបាត់ដំបង និងក្រុងព្រះសីហនុ។

រាជធានីភ្នំពេញ ថ្ងៃទី ខែ មេសា ឆ្នាំ ២០០៨
អ្នកធ្វើរបាយការណ៍

ហ៊្សឹង សុកុល

បានឃើញ និងឯកភាព
នាយកអង្គភាពគ្រប់គ្រងគម្រោង

ស៊ុយ ម៉ុងលាង